ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture,
Forestry and Fisheries

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

លេខ 368 ប្រក.កសក

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មាធិការចុះបញ្ជីកា
## និង ការផ្តល់លិខិតអនុញ្ញាតសេវាកម្មផលិតកម្ម និង បសុព្យាបាល

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកក/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ មិនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និង គ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មាធិការ ចុះបញ្ជីកា ដើម្បីគ្រប់គ្រងអ្នកប្រកបរបរឯកជន លើការងារសេវាកម្មផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ២** : គណៈកម្មាធិការចុះបញ្ជីកា គឺជា សមាសភាពចំរុះ តាមបណ្តា ខេត្ត-ក្រុងនីមួយៗ ដែលរៀបចំឡើងដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានសមាសភាពដូចខាង ក្រោម :-

- តំណាងការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត-ក្រុង មួយរូប ជាប្រធាន
- តំណាងអ្នកចិញ្ចឹមសត្វ មួយរូប ជាសមាជិក

- តំណាងពីររូបដែលត្រូវបានជ្រើសរើសពីជនដែលមានលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល ជាសមាជិក
- មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មួយរូប ( ជាអ្នកចុះបញ្ជីកា ) ជាសមាជិក

ក្នុងករណីគណៈកម្មាធិការមិនទាន់បង្កើតឡើង តំណាងពីររូបជាសមាជិកក្នុងចំណុចទី ៣ ត្រូវឱ្យនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជ្រើសរើសតែងតាំងឡើង ។

ប្រការ ៣ : គណៈកម្មាធិការចុះបញ្ជីកា មានភារកិច្ច :-

- គ្រប់គ្រងបញ្ជីឈ្មោះអ្នកមានលិខិតអនុញ្ញាតទាំងអស់
- លើកសំណើសុំលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាលថ្មី
- លើកសំណើសុំលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាលទាំងអស់ ជាថ្មីឡើងវិញរៀងរាល់ឆ្នាំ
- ព្យួរ ដកហូតលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល ជាបណ្តោះអាសន្នចំពោះជនណាបានប្រព្រឹត្តខុសពីកិច្ចសន្យា និង វិជ្ជាជីវៈរបស់ខ្លួន ដោយមានការសំរេច ពីការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង ហើយត្រូវរាយការណ៍ជូននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ។ ក្នុងករណីលប់ចោលជាស្ថាពរ ត្រូវមានការសំរេចពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។
- ហាមឃាត់ជនគ្មានលិខិតអនុញ្ញាត មិនឱ្យធ្វើសេវាកម្មផលិតកម្ម និង បសុព្យាបាល

ប្រការ ៤ : គណៈកម្មាធិការចុះបញ្ជីកាខេត្ត-ក្រុង ត្រូវមានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ឆមាស ឆ្នាំ និង ប្រជុំវិសាមញ្ញក្នុងករណីចាំបាច់ ហើយរាយការណ៍ជូននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។
សមាសភាពគណៈកម្មការចុះបញ្ជីការខេត្ត-ក្រុង ត្រូវធ្វើការជ្រើសរើសឡើងវិញរៀងរាល់បីឆ្នាំម្តង ។ តែក្នុងករណីចាំបាច់ អាចជ្រើសរើសមុនកាលកំណត់ ។

ប្រការ ៥ : ការចេញលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល សំរេច ដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដោយមាន ការស្នើសុំ របស់សាមីជន តាមរយៈគណៈកម្មាធិការចុះបញ្ជីកា និង ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុងនោះ ។
លិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល គឺជាលិខិតផ្តល់សិទ្ធិមានកាលកំណត់ច្បាស់លាស់ដល់ពលរដ្ឋទាំងពីរភេទ ដើម្បីប្រកបមុខរបរឯកជន ក្នុងវិស័យផលិតកម្ម និង បសុព្យាបាល ។

ប្រការ ៦ : ពលរដ្ឋទាំងពីរភេទ ដែលដាក់ពាក្យសុំលិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល ត្រូវមានលក្ខណៈដូចខាងក្រោម :-

- សុខភាពល្អ អាចបំពេញការងារបាន
- គ្មានជាប់បទល្មើសព្រហ្មទ័ណ្ឌណាមួយ
- មានសញ្ជាតិខ្មែរ

- មានសញ្ញាប័ត្របច្ចេកទេសផលិតកម្ម-បសុព្យាបាល ក្នុង និង ក្រៅប្រទេស ឬ វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ទទួលស្គាល់ដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ឬ សាលាកសិកម្មនៅក្រោមឳវាទ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

ប្រការ ៧ : ពលរដ្ឋទាំងពីរភេទដូចមានចែងក្នុងប្រការ ៦ មានសិទ្ធិស្នើសុំប្រកបសេវាកម្មផលិតកម្ម និង បសុព្យាបាលដូចខាងក្រោម :-

- ពិនិត្យ ព្យាបាល និង ចាក់ថ្នាំការពារសត្វ
- ចិញ្ចឹមសត្វតាមលក្ខណៈបែបឧស្សាហកម្ម
- ផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល ( លក់ថ្នាំ-ចំណីសត្វ ផលិតថ្នាំ-ចំណីសត្វ --- )
- បង្កើតក្រុមអ្នកចិញ្ចឹមសត្វ លក់ថ្នាំ-ចំណីសត្វ ផលិតថ្នាំ-ចំណីសត្វ ជួញដូរសត្វ
- និងការងារចាំបាច់មួយចំនួនទៀត ត្រូវពិភាក្សាជាមួយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

ប្រការ ៨ : ពលរដ្ឋទាំងពីរភេទ ដែលមាន លិខិតអនុញ្ញាតផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល មានសិទ្ធិ រួមសហការដូចខាងក្រោម :-

- ផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និង បសុព្យាបាល ដល់អ្នកចិញ្ចឹម
- ផ្តល់ពត៌មានផលិតកម្ម និង បសុព្យាបាលដល់រដ្ឋអំណាចមូលដ្ឋាន និង ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង នៅពេលចាំបាច់
- ជួយសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុងក្នុងករណីចាំបាច់ ឬពេលមានជំងឺផ្ទុះឡើង
- ធ្វើសំណើទៅ ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង ដើម្បីបំពេញបន្ថែមចំណេះដឹងចាំបាច់
- ភ្នាក់ងារសុខភាពសត្វភូមិ ផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាល ដោយកម្រៃសមស្រប
- ភ្នាក់ងារសុខភាពសត្វភូមិនេះ ស្ថិតនៅក្រៅក្របខ័ណ្ឌមុខងារសាធារណៈ ។

ប្រការ ៩ : ពលរដ្ឋទាំងពីរភេទ ដែលមានលិខិតអនុញ្ញាត ផ្តល់សេវាកម្មផលិតកម្ម និង បសុព្យាបាលហាមឃាត់ធ្វើការងារដូចខាងក្រោម :-

- ត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ប្រមូលទិញ និង ដឹកជញ្ជូនសត្វ
- ត្រួតពិនិត្យ និង ចេញលិខិតអនុញ្ញាតសាងសង់ទីសត្តឃាដ ឬ កន្លែងពិឃាដសត្វ
- អនុញ្ញាតអោយធ្វើអាជីវកម្មពិឃាដសត្វ និង ត្រួតពិនិត្យសាច់ និង ទីសត្តឃាដដ្ឋាន ។

ប្រការ ១០ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

៤

**ប្រការ ១១** : អគ្គនាយក អគ្គាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យាបាល ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ប្រធានការិយាល័យ ផលិតកម្ម និងបសុពេទ្យាបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗ ខ្លួន ។

**ប្រការ ១២** : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី 16 ខែ 8 ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចាន់ - ស៊ុំ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ១១

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ